អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖


- កំណើននៃភ្ញៀវទេសចរក្នុងស្រុកនៃប្រទេសកម្ពុជាបានកើនឡើងជាង១៤%
- វិស័យកសិកម្មនៅកម្ពុជាមានសញ្ញាណវិជ្ជមានគួរឱ្យកត់សំគាល់
- តម្លៃប្រេងសាំងធម្មតាបន្តឡើងថ្លៃដល់ ៤ ១០០រៀលក្នុង១លីត្រ ចំពេលថ្ងៃឈប់សម្រាកភ្ជុំបិណ្ឌ
- កំពង់ស្ពឺ កំពុងប្រឈមការខ្វះកម្លាំងពលកម្ម ខណៈរោងចក្រថ្មីៗចូលមកវិនិយោគជាបន្តបន្ទាប់
- ក្រសួងប្រកាសបើករដូវនេសាទ សម្រាប់រដូវបើកនេសាទ ឆ្នាំ ២០២១-២០២២
- តម្លៃសាច់នៅរដូវភ្ជុំបិណ្ឌឆ្នាំនេះ ថយចុះជាងឆ្នាំមុន
- កម្ពុជានាំចេញកសិផលជិត៦លានតោន ទៅកាន់ទីផ្សារអន្តរជាតិ ទោះបីកូវីដ-១៩តាមរំខាន
- គម្រោងអភិវឌ្ឍន៍កោះទន្សាយនឹងជំរុញលើកកម្ពស់សក្តានុពលទេសចរណ៍ខេត្តកែប
- ធនាគារជាតិនៃកម្ពុជា បន្តដាក់ដេញថ្លៃប្រាក់ដុល្លារអាមេរិកចំនួន២០០លានដុល្លារទៀត នៅដើមខែតុលា
- តុល្យភាពសារពើពន្ធរបស់ប្រទេសសមាជិកអាស៊ានចាប់ពីឆ្នាំ២០១៩-២០២២ (% ផ.ស.ស)
- កំណើនសេដ្ឋកិច្ចវៀតណាមរយៈពេលវែង ថមថយ ដោយសារ កំណើនប្រជាជនវ័យចំណាស់
- វិបត្តិជំងឺកូវីដ-១៩ ប្រទេសចិន បានដើរតួនាទីជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ចសកល
- ពាណិជ្ជកម្មទំនិញសកលឆ្នាំ២០២១ ត្រូវបានព្យាករ មានកំណើន ១០,៨%
- បញ្ហាកង្វះថាមពលកំពុងកើតឡើងនៅក្នុងប្រទេសចិន



ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កំណើននៃភ្ញៀវទេសចរក្នុងស្រុកនៃប្រទេសកម្ពុជាកើនឡើងជាង១៤%



*ប្រភព៖postkhmer, 2021 រូបភាព៖ ហេងជីវ័ន*

យោងតាមទិន្នន័យ បង្ហាញដោយក្រសួងទេសចរណ៍ ភ្ញៀវទេសចរក្នុងស្រុក ដែលបានចេញដើរកម្សាន្តកាលពីសប្តាហ៍ទី១នៃខែតុលា មានចំនួន ១១៦ ៨១៩នាក់ ក្នុងនោះភ្ញៀវជាតិមានចំនួន ១១៣ ៨៥៦នាក់ និងភ្ញៀវបរទេសដែលនៅក្នុងប្រទេសមានចំនួន២ ៩៦៣នាក់។ ចំនួនភ្ញៀវទេសចរដែលមកកម្សាន្តនៅរាជធានីភ្នំពេញមានចំនួន ២៥ ៩៣៤ នាក់, ខេត្តកំពត ២៤ ៧៣២ នាក់, ខេត្តព្រះសីហនុ ១៥ ១៧២ នាក់, ខេត្តកែប ៩ ២៦៦ នាក់, ខេត្តបាត់ដំបង ៦ ៧៥២ នាក់, ខេត្តកណ្តាល ៤ ៦១៦ នាក់, ខេត្តពោធិ៍សាត់ ៤ ៥៧៩ នាក់ និងខេត្តមណ្ឌលគិរី ៤ ២៤៩ នាក់។

សូមបញ្ជាក់ផងដែរ តួលេខនេះបន្តកើនឡើងប្រមាណ ១៤,៤៦%បើធៀបនឹងសប្តាហ៍កន្លងមក។ គោលដៅទេសចរណ៍នានានៅតាមបណ្តារាជធានីខេត្ត បានបើកទទួលភ្ញៀវទេសចរ លើកលែងតែខេត្តកំពង់ឆ្នាំងដែលនៅបន្តដាក់ចេញវិធានការរដ្ឋបាលហាមឃាត់សកម្មភាពមួយចំនួនរួមទាំងរមណីយដ្ឋាន។

តាមការព្យាករ ចំនួនភ្ញៀវទេសចរក្នុងស្រុក នឹងមានចំនួនច្រើនក្នុងសប្តាហ៍នេះ ដោយសារជាអំឡុងពេលនៃពិធីបុណ្យភ្ជុំបិណ្ឌ។ កំណើនភ្ញៀវក្នុងសប្តាហ៍ នេះក៏បង្កើតជាក្តីបារម្ភមួយសម្រាប់រដ្ឋាភិបាល និងវិស័យឯកជនពីការឆ្លងរាលដាលជំងឺកូវីដ- ១៩ ផងដែរ បើទោះបីយុទ្ធនាការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ ១៩ ឱ្យកុមារចាប់ពីអាយុ ៦ ឆ្នាំឡើងទៅ គិតត្រឹមថ្ងៃទី ៤ ខែតុលា មានចំនួនជាង១៣,៤លាននាក់ ឬស្មើនឹង ៨៤,១% ធៀបនឹងចំនួនប្រជាជន ១៦ លាននាក់ក៏ដោយ។

ដើម្បីលើកកម្ពស់សកម្មភាព នៃការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ -១៩ នាយករដ្ឋមន្ត្រី ហ៊ុន សែនបានចេញសារាចរមួយពីការពង្រឹងវិធានការគ្រប់គ្រង ការឆ្លងរាលដាលជំងឺកូវីដ -១៩ សម្រាប់អំឡុងពេល និងក្រោយពេលឈប់សម្រាកក្នុងពិធីបុណ្យភ្ជុំបិណ្ឌ ដោយបានតម្រូវឱ្យក្រសួងស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចយកចិត្តទុកដាក់ឱ្យបានម៉ឺងម៉ាត់ និងប្រកប ដោយស្មារតីទទួលខុសត្រូវ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ -១៩៕ *ដោយ សេន ចន្ទ*

*ប្រភព៖postkhmer ,ចេញផ្សាយថ្ងៃទី០៤ខែតុលា ឆ្នាំ២០២១*

# វិស័យកសិកម្មនៅកម្ពុជាមានសញ្ញាណវិជ្ជមានគួរឱ្យកត់សំគាល់




*រូបថតដោយ៖ Khmer Times*

បើគិតចាប់ពីខែមករាដល់ខែកញ្ញាឆ្នាំ២០២១នេះ កម្ពុជាបាននាំចេញផលិតផលកសិកម្មសរុបប្រមាណជា ៥,៩ លានតោន កើនឡើងចំនួន ៨៨% បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំចាស់ ដែលមានទឹកប្រាក់សរុបចំនួន ៣ ៤៨៩លានដុល្លារ។ ក្នុងនោះការនាំចេញអង្ករមានទំហំ ៣៥០លានដុល្លារ ស្រូវ ៤២៩លានដុល្លារ និងផលិតផលមិនមែនកសិកម្មមានទំហំចំនួន ២ ៧១១ លានដុល្លារ។ បើធៀបទៅនឹងឆ្នាំមុន ការនាំចេញអង្ករបានធ្លាក់ចុះ ១៥,៩% ស្មើនឹង ៤១០ ៦៩៨តោន និងបាននាំចេញទៅកាន់ទីផ្សារអន្តរជាតិចំនួន ៦៨ ខណៈដែលការនាំចេញស្រូវកើនបាន ៨២% ស្មើនឹង ១ ៦២៧ លានតោន។ ការនាំចេញអង្ករមានការធ្លាក់ចុះដោយសារតែថ្លៃដឹកជញ្ជូនមានការកើនឡើងក្នុងអំលុងពេលមានវិបត្តិកូវីដ១៩ ផ្ទុយពីការនាំចេញផលិតផលមិនមែនស្រូវអង្ករមានការកើនឡើង។

ជារួមការនាំចេញផលិតផលមិនមែនកសិកម្មកើនឡើងដល់ទៅ ១០៧%។ ចំណែកឯកំណើនផលិតផលកសិកម្មវិញមានភាពវិជ្ជមាន ដែលក្នុងនោះផលិតផលកសិកម្មនាំចេញសំខាន់ៗរបស់កម្ពុជាមានដូចជា៖ អង្ករ ស្រូវ ស្វាយ ចេក ដំឡូងមី ស្វាយចន្ទី កៅស៊ូ ពោត និងម្រេច។ កាលពីខែសីហាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការកត់សំគាល់ថា បច្ចុប្បន្នកំណើនសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើវិស័យកសិកម្ម ពីព្រោះវិស័យនេះមានកំណើនគួរឱ្យកត់សំគាល់។ ដាក់ស្តែងទិន្នផលស្រូវកាលពីខែកញ្ញាមានការកើនឡើងលើសពីផែនការដែលបានគ្រោងទុក។ គួរបញ្ជាក់ផងដែរថា កាលពីឆ្នាំកន្លងទៅកម្ពុជាបាននាំចេញផលិតផលកសិកម្មជាង ១៣លានតោន ស្មើនឹង ៣ ៤៣៣លានដុល្លារ។

ទន្ទឹមនឹងនេះធនាគារវិនិយោគអឺរ៉ុប (European Investment Bank) បានផ្តល់ទឹកប្រាក់វិនិយោគសរុបប្រមាណជា ១៧,៤លានដុល្លារលើការអភិវឌ្ឍគម្រោងកសិកម្មនៅកម្ពុជា។ ក្នុងនោះទឹកប្រាក់ចំនួន ១០% នឹងត្រូវប្រើប្រាស់សម្រាប់ការត្រៀមរៀបចំសម្រាប់ការអនុវត្តគម្រោងនេះ ដើម្បីជម្រុញដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋចំនួន ២០០ ០០០គ្រួសារនៅទីជនបទ និងដើម្បីបង្កើតការងារចំនួន ៤ ៥០០កន្លែងសម្រាប់យុវជន។ គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីជម្រុញដល់អាជីវកម្មក្នុងវិស័យកសិកម្មនៅកម្ពុជាតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងដើម្បីធានាដល់ការផ្គត់ផ្គង់ស្បៀង។ គួរបញ្ជាក់ផងដែរថា កន្លងមកកម្ពុជាទទួលបានទឹកប្រាក់ជិត ៦០លានដុល្លារតាមរយៈគម្រោងវិនិយោគរបស់ EIB។ ថវិកានេះត្រូវបានចំណាយទៅលើការសាងសង់ផ្លូវក្រាលកៅស៊ូប្រវែង ៦៥០គីឡូម៉ែត្រ និងផ្លូវក្រួស ១៥០គីឡូម៉ែត្រ ដើម្បីធ្វើឱ្យប្រសើរឡើងនូវទីផ្សារជនបទចំនួន ៥០ និងគ្រឿងបរិក្ខារ ២៥ផ្សេងទៀតរួមមាន៖ ចំណតសាឡាង និងទីតាំងប្រមូលផលិតផលកសិកម្ម។ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ គេហទំព័រ Khmer Times ចេញផ្សាយថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១ និង គេហទំព័រ Khmer Times ចេញផ្សាយថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១*

## តម្លៃប្រេងសាំងធម្មតាបន្តឡើងថ្លៃដល់ ៤ ១០០រៀលក្នុង១លីត្រ ចំពេលថ្ងៃឈប់សម្រាកភ្ជុំបិណ្ឌ



*ប្រភព ៖ ខេមបូណូមីស*

នៅអំឡុងថ្ងៃឈប់សម្រាកបុណ្យភ្ជុំបិណ្ឌនេះ តម្លៃប្រេងសាំងធម្មតាបានបន្តឡើងថ្លៃ ១០០រៀលបន្ថែមទៀតក្នុង១លីត្រឯប្រេងម៉ាស៊ូតឡើង១៥០រៀលក្នុង១លីត្រ។ កត្តាដែលធ្វើឱ្យតម្លៃប្រេងឥន្ធនៈនៅកម្ពុជាក៏ដូចជាលើពិភពលោកឡើងថ្លៃ ដោយសារតម្រូវការប្រើប្រាស់ប្រេងមានការកើនឡើង គួបផ្សំមានការកាត់បន្ថយផលិតកម្មប្រេងពីសំណាក់ប្រទេសធំៗ។

បើតាមការចុះផ្សាយរបស់សារព័ត៌មានអន្តរជាតិធំៗ មូលហេតុ ដែលធ្វើឱ្យតម្លៃប្រេងឆៅសកលមានការកើនឡើងដូចនេះ ក៏ដោយសារតែ តម្លៃនៃលុយដោនមានការធ្លាក់ចុះ គួបផ្សំនឹងវិបត្តិថាមពល ដែលកំពុងកើតមាននៅតំបន់អឺរ៉ុប។

ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ប្រេងសាំងធម្មតាត្រូវលក់ចេញក្នុងតម្លៃ៤ ១០០រៀលក្នុង១លីត្រ ខណៈប្រេងម៉ាស៊ូតលក់ចេញ ៣ ៨០០រៀលក្នុង១លីត្រ។

ក្រសួងពាណិជ្ជកម្មពុំមានសិទ្ធិកំណត់ ឬដំឡើងថ្លៃប្រេងឥន្ធនៈនោះទេ ពោលគឺក្រសួងគ្រាន់តែជាអ្នកជួយសម្របសម្រួលនីតិវិធីដល់វិស័យឯកជនតែប៉ុណ្ណោះ។

ជាក់ស្តែងនៅ១សប្តាហ៍ចុងក្រោយនេះ តម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ បានហក់ឡើង៨០ដុល្លារក្នុង១បារ៉ែល ដែលជាការឡើងថ្លៃខ្ពស់មិនធ្លាប់មានកន្លងមកក្នុងរយៈពេល៣ឆ្នាំកន្លងមកនេះ។ តម្លៃប្រេងឆៅលើទីផ្សារអន្តរជាតិនឹងបន្តឡើងថ្លៃ ៩០ដុល្លារក្នុង១បារ៉ែលបន្ថែមនៅចុងឆ្នាំ២០២១។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២១។*

## កំពង់ស្ពឺ កំពុងប្រឈមការខ្វះកម្លាំងពលកម្ម ខណៈរោងចក្រថ្មីៗចូលមកវិនិយោគជាបន្តបន្ទាប់




*ប្រភព ៖ freshnewsasia*

ខេត្តកំពង់ស្ពឺ មានរោងចក្រ សហគ្រាសជាច្រើនបានមកបោះទីតាំងវិនិយោគ។ បច្ចុប្បន្ននេះរោងចក្រជាច្រើនទៀតកំពុងរកទីតាំងសាងសង់ជាបន្តបន្ទាប់។ រោងចក្រជាច្រើននេះមានតម្រូវការពលកម្ម លើសពីចំនួនកម្មករ កម្មការិនី ដែលមាននៅក្នុងខេត្តកំពង់ស្ពឺ ហើយខេត្តកំពុងខ្វះកម្លាំងពលកម្ម ក្នុងវិស័យវាយណភ័ណ្ឌ កាត់សំលៀកបំពាក់ ស្បែកជើង និងកាបូបជាច្រើនពាន់នាក់។

បើតាមឯកឧត្តមអភិបាលខេត្តកំពង់ស្ពឺ បានលើកឡើងថា រោងចក្រកាត់ដេរសំលៀកបំពាក់ ស្បែកជើង បានអំពាវនាវឱ្យយើង ជួយរកកម្លាំងពលកម្មជូនគាត់។ ឯកឧត្តម បានអំពាវនាវដល់ប្រជាពលរដ្ឋ នៅខេត្តជុំវិញកំពង់ស្ពឺ ដូចជាខេត្តកំពង់ឆ្នាំង កណ្តាល តាកែវ កំពតជាដើម ដែលចង់បានការងារក្នុងវិស័យកាត់ដេរ វាយនភ័ណ្ឌ ឱ្យមកបំពេញការងារ នៅខេត្តកំពង់ស្ពឺ។

បច្ចុប្បន្ននៅខេត្តកំពង់ស្ពឺនេះ មានរោងចក្រ សហគ្រាស ចំនួន៣៣៣ ក្នុងនោះរោងចក្រដែលបម្រើឱ្យវិស័យកាត់ដេរសំលៀកបំពាក់ ស្បែកជើង មានចំនួន១៥៣ រោងចក្រ។ ចំណែកម្លាំងកម្មករមានប្រមាណ ១៥ម៉ឺននាក់ ក្នុងនោះកម្មករនិយោជិត បម្រើការងារក្នុងវិស័យកាត់ដេរ មានប្រមាណ១៣ម៉ឺននាក់ និងប្រជាជនសរុបជាង៨៨ម៉ឺននាក់៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖freshnewsasiaចេញផ្សាយថ្ងៃទី០៤ខែតុលាឆ្នាំ២០២១។*

## ក្រសួងប្រកាសបើករដូវនេសាទ សម្រាប់រដូវបើកនេសាទ ឆ្នាំ ២០២១-២០២២



*ប្រភព ៖ postkhmer*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសបើករដូវនេសាទសម្រាប់ការនេសាទក្នុងដែននេសាទទឹកសាប សម្រាប់រដូវបើកនេសាទ ឆ្នាំ ២០២១-២០២២ ក្នុងនោះខេត្តមួយចំនួន នឹងបើកនេសាទចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែឧសភា និងមួយចំនួនទៀត ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

ចំពោះដែននេសាទទឹកសាបដែលត្រូវបើកនេសាទ រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ ព្រះវិហារ រតនគិរី មណ្ឌលគិរី ក្រចេះ ត្បូងឃ្មុំ កំពង់ចាម កំពង់ធំ និងមួយផ្នែកនៃរាជធានីភ្នំពេញ និងខេត្តកណ្ដាល ដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ។ ដោយឡែកខេត្តស្ទឹងត្រែង គឺចាប់ពីថ្ងៃទី០១ ខែតុលានេះ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។

ចំណែកខេត្តព្រៃវែង ស្វាយរៀង តាកែវ កំពង់ស្ពឺ និងមួយផ្នែកនៃរាជធានីភ្នំពេញ និងខេត្តកណ្ដាល ដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ គឺចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២២។

រដ្ឋបាលជលផលបញ្ជាក់ថា អ្នកនេសាទទាំងអស់ត្រូវប្រើឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទស្របតាមច្បាប់ស្ដីពី ជលផល និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ចំពោះអ្នកនេសាទដែលមានបំណងធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍«ម៉ាញ់» នៅដងទន្លេមេគង្គ និងដងទន្លេសាប ក្នុងទីតាំងដែលរាជរដ្ឋាភិបាលបានអនុញ្ញាតត្រូវមកទំនាក់ទំនងសុំលិខិតអនុញ្ញាតពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តពាក់ព័ន្ធ ដើម្បីទទួលការណែនាំពីសមត្ថកិច្ចជំនាញជលផលអំពីបច្ចេកទេស និងបទបញ្ជានានាដែលពាក់ព័ន្ធដល់ការធ្វើនេសាទ៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ postkhmer ចេញផ្សាយថ្ងៃសទី ០៣ ខែតុលា ឆ្នាំ២០២១។*

## តម្លៃសាច់នៅរដូវភ្ជុំបិណ្ឌឆ្នាំនេះ ថយចុះជាងឆ្នាំមុន



*ប្រភព ៖ ខេមបូណ្ឌមីស*

ធ្លាប់តែនៅអំឡុងពេលនៃរដូវបុណ្យភ្ជុំបិណ្ឌ តម្លៃសាច់ជ្រូក មាន់ ទា បានកើនឡើង ប៉ុន្តែរដូវភ្ជុំបិណ្ឌឆ្នាំនេះ តម្លៃបានធ្លាក់ចុះ។ រដូវបុណ្យភ្ជុំបិណ្ឌឆ្នាំនេះ តម្លៃមាន់

រស់ជាមធ្យម ៤ ០០០រៀល ក្នុងមួយគីឡូក្រាមធ្លាក់ចុះតិចតួច ប៉ុន្តែតម្លៃជ្រូករស់មានត្រឹម៩ ០០០រៀលក្នុងមួយគីឡូក្រាម ខុសពីរដូវភ្ជុំបិណ្ឌឆ្នាំមុនៗសត្វជ្រូករស់តម្លៃ១២ ៥០០រៀល ទៅ១៣ ០០០រៀលក្នុងមួយគីឡូក្រាម។

ប្រធានសមាគមចិញ្ចឹមសត្វកម្ពុជា បានបញ្ជាក់ថា បច្ចុប្បន្នកម្ពុជាមានតម្រូវការជ្រូករស់ ប្រមាណ៧ពាន់ក្បាល ទៅ ៨ពាន់ក្បាល ក្នុងមួយថ្ងៃ។ បន្ថែមលើបញ្ហាកូវីដ-១៩ ការផ្អាកពិធីជួបជុំ និងពិធីបុណ្យភ្ជុំ និងការ នាំចូលសត្វខុសច្បាប់ក៏នៅតែជាបញ្ហា សម្រាប់អ្នកប្រកបរបរចិញ្ចឹមសត្វ ក្នុងស្រុកដែរ។

អ្នកចិញ្ចឹមជ្រូកនៅខេត្តពោធិសាត់បានបញ្ជាក់ថា នៅមុនពិធីបុណ្យភ្ជុំបិណ្ឌមកដល់ ជ្រូករស់អាចលក់បានក្នុងតម្លៃ ១ ១០០០រៀល ទៅ ១២ ០០០រៀល ក្នុងមួយគីឡូក្រាម ប៉ុន្តែក្រោយពេលរដូវដាក់បិណ្ឌចូលមកដល់ តម្លៃជ្រូករស់បែរជានៅត្រឹម ១០ ០០០រៀល ប៉ុណ្ណោះក្នុងមួយគីឡូក្រាម ហើយក៏មិនសូវមានឈ្មួញចុះប្រមូលទិញដែរ។

ដោយសារជំងឺកូវីដ-១៩ នៅតែបន្តឆ្លងរាលដាលនៅទូទាំងប្រទេសកម្ពុជា ពិសេសជំងឺកូវីដ-១៩ប្រភេទបំប្លែងថ្មីផងនោះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្អាកពិធីបុណ្យភ្ជុំបិណ្ឌ និងកាន់បិណ្ឌ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី ០១ ខែតុលា ឆ្នាំ២០២១។*

## គម្រោងអភិវឌ្ឍន៍កោះទន្សាយនឹងជំរុញលើកកម្ពស់ សក្តានុពលទេសចរណ៍ខេត្តកែប



*ប្រភព ៖ ខេមបូណ្ឌមីស*

កោះទន្សាយរបស់ខេត្តកែប កំពុងមានពន្លឺជាថ្មី ដែលបច្ចុប្បន្នកោះនេះ កំពុងមានគម្រោងអភិវឌ្ឍន៍ធំមួយដោយក្រុមហ៊ុនក្នុងស្រុក ចំណាយថវិកាប្រមាណ ១៣០លានដុល្លារអាមេរិក បានបើកការដ្ឋានសាងសង់ ហើយគ្រោងនឹងបញ្ចប់ នៅ២ទៅ៣ឆ្នាំខាងមុខនេះ។ ក្រោយគម្រោងនេះបញ្ចប់ការសាងសង់ជាស្ថាពរ វានឹងក្លាយមេដែកក្នុងការស្រូបទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកកម្សាន្តនៅខេត្តជាប់មាត់សមុទ្រមួយនេះកាន់តែច្រើនថែមទៀត នឹងជួយបង្កើនរយៈពេលការធ្វើដំណើរកម្សាន្តរបស់ភ្ញៀវទេសចរកាន់តែយូរជាងមុន។

គម្រោងអភិវឌ្ឍន៍នៅលើកោះទន្សាយរួមមាន សណ្ឋាគារលំដាប់ផ្កាយ២, រីសត, អាហារដ្ឋាន, ឆ្នេរខ្សាច់, អគារពាណិជ្ជកម្ម និងអគារផ្សេងៗ។

គម្រោងអភិវឌ្ឍន៍កោះទន្សាយ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់សិទ្ធិអភិវឌ្ឍន៍ដល់ក្រុមហ៊ុន ទ្រី ភាព គ្រុម ដែលពីមុនរាជរដ្ឋាភិបាលបានប្រគល់សិទ្ធិអភិវឌ្ឍន៍ដល់ក្រុមចំនួនពីររួចមកហើយ ប៉ុន្តែត្រូវបាន ដកហូតសិទ្ធិមកវិញដោយសារពុំមានសកម្មភាព ក្រោយបានទទួលសិទ្ធិពីរដ្ឋ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០១ខែតុលា ឆ្នាំ២០២១។*

## ធនាគារជាតិនៃកម្ពុជា បន្តដាក់ដេញថ្លៃប្រាក់ដុល្លារអាមេរិកចំនួន២០០លានដុល្លារទៀត នៅដើមខែតុលា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៤៦៥-០២១ ៣/០៩ ធ.ជ.ក.ឯ

ថ្ងៃ ព្រហស្បតិ៍ ៩កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការដាក់ឱ្យដេញថ្លៃប្រាក់ដុល្លារអាមេរិក**

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជូនដំណឹងដល់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ដែលមានអាជ្ញាបណ្ណទាំងអស់ មេត្តាជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យដេញថ្លៃប្រាក់ដុល្លារអាមេរិកចំនួនប្រមាណ ២០០.០០០.០០០ ដុល្លារអាមេរិក (ពីររយលានដុល្លារអាមេរិក) សម្រាប់ខែតុលា ឆ្នាំ២០២១នេះ។ ទន្ទឹមនេះ ការដេញថ្លៃនឹងធ្វើឡើងជាដំណាក់កាលៗ ចំពោះកាលបរិច្ឆេទ និងទំហំទឹកប្រាក់ដេញថ្លៃជាក់ស្តែងនឹងជូនដំណឹងនាពេលក្រោយទៀត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ដែលមានអាជ្ញាបណ្ណទាំងអស់ជ្រាបជាព័ត៌មាន និងត្រៀមលក្ខណៈចូលរួមការដេញថ្លៃតាមការគួរ។

ធនាគារជាតិនៃកម្ពុជាសូមរក្សាសិទ្ធិក្នុងការកែសម្រួលទំហំទឹកប្រាក់សរុបដាក់ឱ្យដេញថ្លៃទៅតាមស្ថានភាពទីផ្សារជាក់ស្តែង។

សូមទំនាក់ទំនង៖
លេខទូរសព្ទ : (៨៥៥-២៣) ៨២៨ ៨៥០
អ៊ីម៉ែល : rmteam.fxexnbc@nbc.org.kh

*ប្រភព ៖ ធនាគារជាតិនៃកម្ពុជា*

ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីជូនដំណឹងដល់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ ដើម្បីឱ្យចូលរួមដាក់ឱ្យដេញថ្លៃប្រាក់ដុល្លារអាមេរិកចំនួន ២០០ ០០០ ០០០ដុល្លារអាមេរិក សម្រាប់ខែតុលា ឆ្នាំ២០២១នេះ។ ការដេញថ្លៃនឹងធ្វើឡើងជាដំណាក់កាលៗ ចំពោះការបរិច្ឆេទ និងទំហំទឹកប្រាក់ដេញថ្លៃជាក់ស្តែង នឹងជូនដំណឹងនៅពេលក្រោយទៀត។

កាលពីខែកញ្ញាកន្លងមក ធនាគារជាតិបានបញ្ចេញប្រាក់ដុល្លារអាមេរិក១០០លានដុល្លារ សម្រាប់ដាក់ឱ្យមានការដេញថ្លៃមួយលើករួចហើយ។

នេះ គឺជាប្រតិបត្តិការទប់ទល់នឹងការប្រែប្រួលតម្រូវការ និងការផ្គត់ផ្គង់រូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក និងប្រាក់រៀលនៅលើទីផ្សារប្តូរប្រាក់ ដើម្បីរក្សាតម្លៃប្រាក់រៀល និងការពារអំណាចទិញរបស់ប្រាក់រៀល ដែលជាចំណូលរបស់ជនទូទៅ ជាពិសេសប្រជាកសិករ និងប្រជាជន ដែលមានចំណូលទាប។

ធនាគារជាតិនៃកម្ពុជាបានរក្សាស្ថិរភាពតម្លៃប្រាក់រៀលបានយ៉ាងល្អប្រសើរ ពង្រឹងជំនឿទុកចិត្ត លើកទឹកចិត្តសាធារណជនឱ្យប្រើប្រាស់ និងសន្សំជាប្រាក់រៀល។

ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធានការប្រមូលប្រាក់រៀល តាមរយៈការបញ្ចេញប្រាក់ដុល្លារអាមេរិកដាក់ឱ្យគ្រឹះស្ថានធនាគារ មីក្រូហិរញ្ញវត្ថុ និងអាជីវកររកស៊ីប្តូរប្រាក់ដែលមានលិខិតអនុញ្ញាតត្រឹមត្រូវដេញថ្លៃជាបន្តបន្ទាប់៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖freshnewsasiaចេញផ្សាយថ្ងៃទី៣០ខែកញ្ញាឆ្នាំ២០២១។*
*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២២ខែកញ្ញា ឆ្នាំ២០២១។*

## អគ្គនាយកដ្ឋានពន្ធដារពន្យាពេលបន្ថែមដល់ពលរដ្ឋទៅបង់ពន្ធលើអចលទ្រព្យសម្រាប់ឆ្នាំ២០២១ រហូតដល់ចុងខែតុលាខាងមុខនេះ




*ប្រភព ៖ ខេមបូណូមីស*

ដើម្បីសម្រួលដល់ម្ចាស់អចនទ្រព្យទាំងអស់ អគ្គនាយកនាយកដ្ឋានពន្ធដារ បានពន្យាពេលការប្រមូលការបង់ពន្ធលើអចលទ្រព្យ រហូតដល់ថ្ងៃទី៣១ ខែតុលា ខាងមុខនេះ។

រហូតមកទល់ពេលនេះ នៅមានម្ចាស់អចលនទ្រព្យមួយចំនួន មិនទាន់បានមកបង់ពន្ធប្រភេទនេះនៅ

ឡើយទេ។ បើតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ម្ចាស់អចលនទ្រព្យ ត្រូវមានកាតព្វកិច្ចប្រកាសពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ ផុតរយៈពេលនេះ ម្ចាស់អចលនទ្រព្យនឹងត្រូវទទួលរងទោសទណ្ឌស្របតាមច្បាប់ស្តីពី សារពើពន្ធជាធរមាន។

ក៏ប៉ុន្តែ ដើម្បីផ្តល់លទ្ធភាព ដល់ម្ចាស់អចលនទ្រព្យដែលមានឆន្ទៈ ក្នុងការបំពេញកាតព្វកិច្ច ប្រកាសបង់ពន្ធនេះ ប៉ុន្តែមិនទាន់បានមកប្រកាសបង់ពន្ធដោយសារការរីករាលដាលជំងឺកូវីដ-១៩ អគ្គនាយកដ្ឋានពន្ធដារ សម្រេចពន្យារកាលបរិច្ឆេទ ផុតកំណត់ប្រកាសបង់ពន្ធ លើអចលនទ្រព្យសម្រាប់ឆ្នាំ២០២១ រហូតដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១។

ដើម្បីបង្កភាពងាយស្រួល និងចំណេញពេលវេលា អគ្គនាយកដ្ឋានពន្ធដារ បានណែនាំឱ្យម្ចាស់អចលនទ្រព្យទាំងអស់អាចប្រកាសនិងបង់ពន្ធលើអចលនទ្រព្យតាមកម្មវិធីទូរស័ព្ទដៃ GDT Taxpayer App ដែលអាចទាញយកកម្មវិធីនេះបានពីAppstore ឬ Playstore៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១ ៖ ទេសចរបរទេសបានធ្វើដំណើរចូលមកប្រទេសកម្ពុជានៅក្នុងខែកក្កដា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ក្រសួងទេសចរណ៍នៃប្រទេសកម្ពុជាបានបង្ហាញថា៖ នៅក្នុងខែកក្កដា ឆ្នាំ ២០២១ ទេសចរបរទេសបានធ្វើដំណើរចូលមកកម្ពុជាមានចំនួន ៩ ៩៨៤នាក់ ដែលមានការធ្លាក់ចុះប្រមាណជា៨,៩% បើធៀបនឹងខែមិថុនា ឆ្នាំ២០២១។ នៅក្នុងខែកក្កដា ឆ្នាំ២០២១នេះដែរ ទេសចរបរទេសដែលបាន ធ្វើដំណើរចូលមកកម្ពុជាច្រើនជាងគេទាំង១០ប្រទេស រួមមាន៖ប្រទេសថៃមានចំណែកច្រើនគេបំផុត ប្រហែល ៤១% នៃចំនួនទេសចរបរទេសសរុប និងប្រទេសចិនឈរនៅលំដាប់ទី២ ដែលមានចំណែក ២៧,៤%។ ដោយឡែក ប្រទេសវៀតណាម មានចំណែក ៥,៦% អាមេរិក ៤,៧% កូរ៉េខាងត្បូង ៣,៤% តៃវ៉ាន់ ២,៩% បារាំង២,២% ឥណ្ឌូនេស៊ី១,៨% ម៉ាឡេស៊ី១,២% និងហ្វីលីពីន ១,១% នៃចំនួនទេសចរបរទេសសរុប៕ *ដោយ មិត្ត ចន្ទី*

*ឯកតា៖គិតជា(នាក់)*

| បរិយាយ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា |
|---|---|---|---|---|---|---|---|
| ទេសចរបរទេស | 20,567 | 20,580 | 29,754 | 11,938 | 8,757 | 10,964 | 9,984 |
| ការប្រែប្រួល(%) | | 0.1% | 44.6% | -59.9% | -26.6% | 25.2% | -8.9% |

*ប្រភព៖ក្រសួងទេសចរណ៍*

### តារាងទី២ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសថៃលើមុខទំនិញ នៅក្នុងខែសីហា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ធនាគារជាតិប្រទេសថៃ បានបង្ហាញថា៖ នៅក្នុងខែសីហា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសថៃ មានទំហំទឹកប្រាក់សរុប ៦២៥,២៧លានដុល្លារ ដែលមានការធ្លាក់ចុះបន្តិចប្រមាណជា ០,៨% បើធៀបនឹងខែកក្កដា ឆ្នាំ២០២១។ ជាក់ស្តែង ការនាំចូលទំនិញរបស់ប្រទេសថៃ មកកម្ពុជា មានទំហំទឹកប្រាក់ ៥៧០,៧៦លានដុល្លារ នៅក្នុងខែសីហា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ១,២% បើធៀបនឹងខែកក្កដា។

ក៏ប៉ុន្តែ ការនាំចេញទំនិញរបស់កម្ពុជាទៅប្រទេសថៃ មានទំហំទឹកប្រាក់ប្រមាណជា៥៤,៥១លានដុល្លារ នៅ

ក្នុងខែសីហាឆ្នាំ២០២១ដែលមានកំណើនប្រមាណជា ២,៩% បើធៀបនឹងខែកក្កដា ឆ្នាំ២០២១។

*ដោយ មិត្ត ចន្ទី*

***ឯកតា៖ គិតជាលានដុល្លារអាមេរិក***

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **653.39** | **644.76** | **799.19** | **596.61** | **671.83** | **616.20** | **630.47** | **625.27** |
| កំណើន% | | -1.3% | 24.0% | -25.3% | 12.6% | -8.3% | 2.3% | -0.8% |
| កម្ពុជានាំចេញទៅថៃ | 113.22 | 112.05 | 104.27 | 72.63 | 57.65 | 55.93 | 52.97 | 54.51 |
| កំណើន% | | -1.0% | -6.9% | -30.3% | -20.6% | -3.0% | -5.3% | 2.9% |
| ថៃនាំចូលមកកម្ពុជា | 540.17 | 532.71 | 694.92 | 523.98 | 614.18 | 560.27 | 577.50 | 570.76 |
| កំណើន% | | -1.4% | 30.4% | -24.6% | 17.2% | -8.8% | 3.1% | -1.2% |

*ប្រភព៖ធនាគារជាតិប្រទេសថៃ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### តុល្យភាពសារពើពន្ធរបស់រដ្ឋនៅក្នុងប្រទេសសមាជិកអាស៊ានចាប់ពីឆ្នាំ២០១៩-២០២២ (% ផ.ស.ស)




*ប្រភព៖ AMRO-AREO*

យោងតាមការព្យាករណ៍របស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (ASEAN+3 Macroeconomic Research Office) តុល្យភាពសារពើពន្ធរបស់បណ្តាប្រទេសសមាជិកអាស៊ានទាំងដប់ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ មានឱនភាពជារៀងរាល់ឆ្នាំ ដែលមានទំហំជាមធ្យមចាប់ពី -២,៩% នៃ ផ.ស.ស ដល់ -៦,៩% នៃ ផ.ស.ស។ គួរកត់សំគាល់ថា ឱនភាពសារពើពន្ធនៅក្នុងប្រទេសអាស៊ានទាំងដប់ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ស្ថិតនៅក្រោម -១៤% នៃ ផ.ស.ស។ ប៉ុន្តែឱនភាពសារពើពន្ធរបស់បណ្តាប្រទេសអាស៊ាននៅក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ហាក់មានទំនោរកើនឡើង ដោយសារតែរដ្ឋាភិបាលនៅតាមបណ្តាប្រទេសសមាជិកអាស៊ានទាំងដប់ត្រូវបង្កើនការចំណាយ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ និងដើម្បីទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនៅក្នុងអំលុងពេលមានវិបត្តិកូវីដ១៩។ បើកាលណាឱនភាពសារពើពន្ធមានទំហំកាន់តែធំ នោះបំណុលរបស់ប្រទេសនោះក៏នឹងកើនទៅតាមនោះដែរ ព្រោះតុល្យភាពសារពើពន្ធបានមកពីចំណូលរបស់រដ្ឋដកឱ្យចំណាយរបស់រដ្ឋ។ យោងតាមរូបខាងលើ នៅក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២២ ឱនភាពសារពើពន្ធរបស់បណ្តាប្រទេសអាស៊ានមានទំហំតូចជាងឆ្នាំ២០២០ និងឆ្នាំ២០២១ គឺស្ថិតនៅក្នុងចម្លោះពី -១,២% នៃផ.ស.ស ដល់ -៧,៦% នៃផ.ស.ស ប៉ុណ្ណោះ។ ដោយឡែកនៅក្នុងឆ្នាំ២០២០ តុល្យភាពសារពើពន្ធរបស់ប្រទេសសឹង្ហបុរីហាក់មានឱនភាពខ្លាំងជាងគេ មានទំហំដល់ទៅ -១៣,៩% នៃ ផ.ស.ស។ បន្ទាប់មកឱនភាពសារពើពន្ធរបស់ប្រទេសព្រុយណេនៅក្នុងឆ្នាំ២០២០ ឈរនៅលំដាប់លេខរៀងទី២ គឺមានទំហំស្មើនឹង -១១,១% នៃ ផ.ស.ស។ ចំណែកឯប្រទេសដែលមានឱនភាពសារពើពន្ធទាប

ជាងគេនៅក្នុងឆ្នាំ២០២០ នៅក្នុងចំណោមប្រទេសទាំងដប់ គឺប្រទេសវៀតណាម ដែលមានឱនភាពសារពើពន្ធត្រឹមតែ -៣,៤% នៃ ផ.ស.ស ប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងឆ្នាំ២០២១ តុល្យភាពសារពើពន្ធរបស់ប្រទេសហ្វីលីពីនមានឱនភាពខ្ពស់ជាងគេនៅក្នុងទំហំប្រមាណជា -៩,១% នៃ ផ.ស.ស។ បន្ទាប់មកគឺប្រទេសកម្ពុជាមានទំហំស្មើនឹង -៨,០% នៃ ផ.ស.ស។ ជារួមចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ ឱនភាពសារពើពន្ធនៅក្នុងបណ្តាប្រទេសអាស៊ានទាំងដប់ស្ថិតនៅក្នុងចន្លោះពី-១,២% នៃ ផ.ស.ស ដល់-១៣,៩% នៃផ.ស.ស៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ AMRO ចេញផ្សាយឆ្នាំ២០២១*

## កំណើនសេដ្ឋកិច្ចវៀតណាមរយៈពេលវែង ថមថយល្បឿន ដោយសារ ការកើនឡើងនៃចំនួនប្រជាជនវ័យចំណាស់



*ប្រភព៖ TheStar ២០២១*

យោងតាមរបាយការណ៍ ផលិតរួមដោយធនាគារពិភព-លោក(World Bank) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(Japan International Cooperation Agency, JICA) បង្ហាញថា ប្រទេសវៀតណាមបានកំពុងនឹងឆ្លងកាត់ការផ្លាស់ប្តូរប្រជាសាស្ត្រ ទៅជាសង្គមប្រជាជនវ័យចំណាស់ ដែលអាចនាំឱ្យកំណើនសេដ្ឋកិច្ចវៀតណាមរយៈពេលវែង ឆ្នាំ២០២០-២០៥០ ថមថយល្បឿន ០,៩ពិន្ទុភាគរយ បើធៀបនឹងកំណើនក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ។ ក្នុងបរិការណ៍នេះ វៀតណាមអាចនឹងជួបប្រទះបញ្ហាប្រឈមសំខាន់ៗ ដែលតម្រូវឱ្យមានការសម្រេចលើជម្រើសគោលនយោបាយចាំបាច់។

ក្នុងនោះដែរ របាយការណ៍នេះ បានប៉ាន់ប្រមាណថា នៅត្រឹមឆ្នាំ២០៣៥ ចំនួនប្រជាជនវ័យចំណាស់ នឹងមានចំនួនប្រមាណជា ១០% ទៅជិត ២០%នៃចំនួនប្រជាជនសរុប ដែលនេះបណ្តាលមកពីការធ្លាក់ចុះនៃអត្រាកំណើត និងការកើនឡើងនៃអាយុកាលជាមធ្យមនៃប្រជាជន ដែលជាលទ្ធផល អនុបាតអាស្រ័យតាមអាយុ(Age Dependency Ratio) ត្រូវបានប៉ាន់ស្មានមានកំណើនទ្វេដង ពី ០,១១ នៅឆ្នាំ២០១៩ ទៅ ០,២២ នៅឆ្នាំ២០៣៩។ ទន្ទឹមនេះដែរ ការដោះស្រាយលើបញ្ហាសង្គមប្រជាជនវ័យចំណាស់ ត្រូវការចំណាយបន្ថែមក្នុងទំហំប្រមាណជាពី ១,៤% ទៅ ៤,៦%នៃផ.ស.ស។

គួរបញ្ជាក់ថា របាយការណ៍នេះ ក៏បានផ្តល់អនុសាសន៍លើការគ្រប់គ្រងសង្គមប្រជាជនវ័យចំណាស់ តាមរយៈការលើកឡើងពីកំណែទម្រង់ ដើម្បីកែលម្អផលិតភាព និងការចូលរួមក្នុងកម្លាំងពលកម្ម ការបង្កើនប្រសិទ្ធិភាពនៃចំណាយសាធារណៈ និងការពង្រឹងលើការផ្តល់សេវាសាធារណៈ ក៏ដូចជា វិធានគោលនយោបាយក្នុងវិស័យដែលទទួលរងផលប៉ះពាល់ផ្ទាល់ រួមមាន ទីផ្សារពលកម្ម សោធននិវត្តន៍ សុខាភិបាល និងការថែទាំមនុស្សចាស់ជរា។ អនុសាសន៍ទាំងនេះ ផ្អែកលើបទពិសោធន៍ពីប្រទេសនានា ដែលបានឆ្លងកាត់លើការផ្លាស់ប្តូរប្រជា-សាស្ត្រដែលមានលក្ខណៈស្រដៀង ជាពិសេសប្រទេសជប៉ុន៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ TheStar ចេញផ្សាយ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១*

## កំណើនសេដ្ឋកិច្ចថៃ និងឥណ្ឌូនេស៊ី ទាបជាងការព្យាករ

**Economic growth forecast for ASEAN 5, India and China** *(Change from a year earlier, in percent)*

| | 2021 | | | '22 | | | | | |
|---|---|---|---|---|---|---|---|---|---|
| | Q2 | Q3 | Q4 | Q1 | Q2 | '20 | '21 | '22 | '23 |
| **ASEAN5** | 9.9 | 2.2 (5.1) | 3.7 (4.7) | 3.9 (4.7) | 4.8 | -4.8 | 3.5 (4.1) | 5.0 (5.2) | 4.8 (4.6) |
| Indonesia | 7.1 | 3.1 (5.4) | 4.8 (4.8) | 4.9 (5.0) | 4.7 | -2.1 | 3.5 (4.1) | 5.0 (4.9) | 5.1 (5.1) |
| Malaysia | 16.1 | -2.4 (3.9) | 3.9 (6.5) | 4.8 (6.0) | 6.9 | -5.6 | 3.8 (4.1) | 6.2 (6.5) | 4.9 (5.3) |
| Philippines | 11.8 | 4.6 (6.6) | 5.2 (5.5) | 5.9 (5.8) | 7.5 | -9.6 | 4.3 (4.3) | 6.6 (6.2) | 5.8 (5.5) |
| Singapore | 14.7 | 6.8 (8.1) | 4.9 (4.5) | 3.1 (3.5) | 5.1 | -5.4 | 6.8 (6.9) | 4.4 (3.9) | 3.5 (2.6) |
| Thailand | 7.5 | -1.2 (2.2) | -0.9 (2.7) | 0.5 (3.1) | 1.6 | -6.1 | 0.5 (1.9) | 3.4 (4.9) | 4.5 (3.7) |
| **India** | 20.1 | 8.4 (8.1) | 6.4 (6.5) | 6.5 (5.2) | 12.6 | -7.3 | 9.4 (9.7) | 7.5 (7.5) | 6.0 (6.4) |
| **China** | 7.9 | – | – | – | – | 2.3 | – (8.6) | – (5.5) | – (5.2) |

*Forecasts are for 2021 onward; figures in parentheses represent average forecasts as of the previous survey in June 2021; annual figures for India are those of fiscal year (April - March)*
*Source: JCER/Nikkei Consensus Survey, Nikkei/NQN Survey, Haver Analytics*

*ប្រភព៖ Nikkei Asia ២០២១*

Nikkei និងវិទ្យាស្ថានជប៉ុនសម្រាប់ការស្រាវជ្រាវសេដ្ឋកិច្ច (The Japan Center for Economic Research) បានផលិតការស្ទង់មតិប្រចាំត្រីមាស តាមរយៈការប្រមូលការឆ្លើយតបពីសេដ្ឋវិទូចំនួន ៣៩រូប ក្នុងប្រទេសជាសមាជិកអាស៊ានធំចំនួន ០៥ (ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ) និងប្រទេសឥណ្ឌា។ យោងតាមលទ្ធផលនៃការស្ទង់មតិនេះ បង្ហាញថា អ្នកសេដ្ឋកិច្ចបានធ្វើការបន្ទាបការព្យាករកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសមួយចំនួននៅអាស៊ី ដែលក្នុងនោះមាន ប្រទេសថៃ និងប្រទេសឥណ្ឌូនេស៊ី ដោយសារតែបញ្ហាពាក់ព័ន្ធនឹងវិបត្តិជំងឺរាតត្បាតកូវីដ-១៩ ដែលបានរំខានទៅដល់ការប្រើប្រាស់ និងការផលិតក្នុងត្រីមាសទី៣ ឆ្នាំ២០២១នេះ។

បន្ថែមពីនេះទៀត កំណើនជាមធ្យមសម្រាប់ប្រទេសជាសមាជិកអាស៊ានទាំង៥នេះ នៅឆ្នាំ២០២១ ត្រូវបានព្យាករថា មានអត្រា ៣,៥% ដែលទាបជាងការព្យាករក្នុងការស្ទង់មតិកាលពីខែមិថុនា ចំនួន ០,៦ពិន្ទុភាគរយ។ ដោយឡែក ចំពោះទស្សនវិស័យកំណើនសេដ្ឋកិច្ចថៃ ឆ្នាំ២០២១ មានកំណើនទាបជាងគេបំផុត នៅអត្រា ០,៥% ដែលបានធ្លាក់ចុះ ១,៤ពិន្ទុ ពីការស្ទង់មតិលើកមុន។ ចំណែកឯ ប្រទេសឥណ្ឌូនេស៊ី ការព្យាករកំណើនសេដ្ឋកិច្ច ក៏ត្រូវបានទម្លាក់ពី ៤,១% មកត្រឹម ៣,៥% ដែលជាសេដ្ឋកិច្ចមានកំណើនទាបបំផុតទី២ ក្នុងចំណោមប្រទេសសមាជិកអាស៊ានធំទាំង៥។

គួរបញ្ជាក់ថា ក្រៅពីផលប៉ះពាល់ដែលពាក់ព័ន្ធនឹងជំងឺរាតត្បាតកូវីដ-១៩ គោលនយោបាយរូបិយវត្ថុអាមេរិក គឺជាហានិភ័យចម្បងទៅលើសេដ្ឋកិច្ចអាស៊ី ក្នុងរយៈពេល ១២ខែខាងមុខ។ រីឯ ការថមថយល្បឿននៃសេដ្ឋកិច្ចចិន ត្រូវបានចាត់ទុកជាគ្រោះថ្នាក់ធំទី២ ចំពោះសេដ្ឋកិច្ចម៉ាឡេស៊ី។ *ដោយ មុំ ចិន្តា*

*ប្រភព៖ Nikkei Asia ចេញផ្សាយ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១*

## ថៃតម្រង់គោលដៅចាប់យកភ្ញៀវទេសចរឥណ្ឌាជំនួសឱ្យការបាត់បង់ភ្ញៀវទេសចរចិន



*ប្រភព ៖ ខេមបូណ្ឌមីស*

ប្រទេសថៃ បាននិងកំពុងរៀបចំផែនការទាក់ទាញភ្ញៀវទេសចរឥណ្ឌា អំឡុងពេលឈប់សម្រាកនៃរដូវបុណ្យប្រពៃណីនៃសាសនាហិណ្ឌូនាពេលខាងមុខនេះ។ ក្រុមប្រឹក្សាទេសចរណ៍ថៃ ជឿជាក់ថា ប្រជាជនឥណ្ឌាដែលជាក្រុមភ្ញៀវទេសចរច្រើនលំដាប់ទី ៣ នៅក្នុងប្រទេសថៃ នឹងធ្វើដំណើរកម្សាន្តមកកាន់ប្រទេសថៃច្រើនឡើងវិញ សម្រាប់ការលំហែកម្សាន្ត ធ្វើសន្និសីទធំៗ

និងរៀបចំអាពាហ៍ពិពាហ៍ជាដើម។ ហើយប្រសិនបើថៃមានផែនការបើកប្រទេស និងតំបន់ទេសចរណ៍ជាច្រើន នៅក្នុងខែវិច្ឆិកានេះ ពិធីបុណ្យសាសនារបស់ឥណ្ឌា គឺជាឱកាសក្នុងការចាប់យកអ្នកដំណើរឥណ្ឌាពោរពេញទៅដោយសក្តានុពល និងធនធានក្នុងការចំណាយ។ អ្នកដំណើរឥណ្ឌា អាចនឹងចំណាយចន្លោះពី៨០០ដុល្លារ ទៅ ២ ២០០ដុល្លារអាមេរិក ក្នុងដំណើរកម្សាន្តមួយលើក មកកាន់ប្រទេសថៃ។ កាលពីឆ្នាំ ២០១៩ ភ្ញៀវទេសចរឥណ្ឌា ប្រមាណ ២លាននាក់ចូលមកកម្សាន្តនៅក្នុងប្រទេសថៃ ។

នៅក្នុងរយៈពេល ៨ខែ ដើមឆ្នាំ ២០២១នេះ ប្រទេសថៃ ទទួលបានភ្ញៀវទេសចរបរទេសប្រមាណជាង ៧ម៉ឺននាក់ប៉ុណ្ណោះ។ វិស័យទេសចរណ៍ បានចូលរួមចំណែកដ៏ធំប្រមាណ ១ភាគ៥ នៃសេដ្ឋកិច្ចរបស់ប្រទេសថៃ។ វិស័យទេសចរណ៍របស់ថៃ អាចនឹងត្រូវការពេលវេលា ៥ឆ្នាំ ដើម្បីត្រលប់មករកសភាពដើមវិញ ដែលជាសញ្ញាមិនល្អសម្រាប់ប្រទេសថៃ។

អ្នកសេដ្ឋកិច្ចជាន់ខ្ពស់នៃធនាគារពិភពលោកប្រចាំប្រទេសថៃ បានលើកឡើងថា វិស័យទេសចរណ៍ទំនងជាមិនអាចក្រោកឡើងវិញ ក្នុងឆ្នាំ២០២១នេះទេ ហើយរំពឹងនឹងទទួលបានភ្ញៀវទេសចរបរទេស ១៦ម៉ឺននាក់ប៉ុណ្ណោះ មុននឹងកើនឡើងវិញដល់ ១លាន ៧សែននាក់ នៅក្នុងឆ្នាំ ២០២២ខាងមុខ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី៣០ខែកញ្ញា ឆ្នាំ២០២១។*

## សេដ្ឋកិច្ចសកល

### ក្នុងកំឡុងវិបត្តិជំងឺរាតត្បាតជំងឺកូវីដ-១៩ ប្រទេសចិនបានដើរតួនាទីជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ចសកល



*ប្រភព៖ Khmer Times ២០២១, រូបភាព៖ Wang Jilin/Xinhua*

លោក Coleman Nee អ្នកសេដ្ឋកិច្ចជាន់ខ្ពស់មកពីអង្គការពាណិជ្ជកម្មពិភពលោក បានផ្តល់ព័ត៌មានទៅកាន់សារព័ត៌មាន Xinhua ថា ប្រទេសចិនគឺជាកម្លាំងចលករកំណើនសម្រាប់ពិភពលោក ក្នុងកំឡុងវិបត្តិជំងឺកូវីដ-១៩នេះ។ លោកបានលើកឡើងថា ពាណិជ្ជកម្មទំនិញ បានងើបឡើងវិញយ៉ាងលឿន នេះដោយសារតែប្រទេសមួយចំនួន ដែលមានប្រទេសចិន បានធ្វើការផ្គត់ផ្គង់ទំនិញសំខាន់ៗ ឧបករណ៍បរិក្ខារពេទ្យ និងទំនិញផ្សេងៗ ទៅកាន់ពិភពលោក។

ទន្ទឹមនេះដែរ ក្រៅពីទំនិញទូទៅ ប្រទេសចិន ក៏បានផ្គត់ផ្គង់ម៉ាស់ច្រើនជាង ៣២០ប៊ីលាន ឈុតការពារចំនួន ៣,៩ប៊ីលាន និងឧបករណ៍តេស្ត Acid Nucleic ចំនួន ៥,៦ប៊ីលាន យោងតាមតួលេខផ្លូវការរបស់រដ្ឋាភិបាលប៉េកាំង។

យោងតាមការព្យាករកាលពីខែមីនា អង្គការពាណិជ្ជកម្មពិភពលោករំពឹងថា ទំហំពាណិជ្ជកម្មទំនិញសកលនឹងមានកំណើន ៨% នៅឆ្នាំ២០២១ បន្ទាប់ពីការធ្លាក់ចុះ ៥,៣% នៅឆ្នាំ២០២០ និងមានកំណើន ៤% នៅឆ្នាំ

២០២២ ប៉ុន្តែ នៅតែស្ថិតក្រោមទំហំពាណិជ្ជកម្មទំនិញសរុបមុនវិបត្តិ។ ដោយឡែក ទស្សនវិស័យលើពាណិជ្ជ-កម្មសេវាកម្ម នៅតែមិនទាន់ភាពប្រាកដប្រជា ដោយសារការប៉ះទង្គិចយ៉ាងខ្លាំងលើពាណិជ្ជកម្មសេវាកម្ម ជាពិសេស ការបម្រាមលើការធ្វើដំណើរទេសចរ។

បន្ថែមពីនេះ អ្នកសេដ្ឋកិច្ចដដែលនេះ បានគូសសម្គាល់ថា ប្រទេសចិន បានប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព តាមរយៈការជំរុញសមត្ថភាពលើការទទួលវ៉ាក់សាំង ក៏ដូចជា កិច្ចប្រឹងប្រែងក្នុងការធ្វើឱ្យវ៉ាក់សាំងក្លាយជាទំនិញសាធារណៈសកល និងការជំរុញលទ្ធភាព និងការទទួលបានវ៉ាក់សាំងសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Khmer Times ចេញផ្សាយ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១*

## ពាណិជ្ជកម្មទំនិញសកលឆ្នាំ២០២១ ត្រូវបានព្យាករមានកំណើន ១០,៨%



*ប្រភព៖ World Economic Times ២០២១*

ថ្មីៗនេះ អង្គការពាណិជ្ជកម្មពិភពលោក បានធ្វើការកែតម្រូវឡើងវិញ ទៅលើការព្យាករកំណើនពាណិជ្ជកម្មទំនិញសកលនៅឆ្នាំ២០២១ ដោយបានបង្កើនពីអត្រាកំណើន ៨%(ព្យាករកាលពីខែមីនា) ទៅ ១០,៨%។ គួរបញ្ជាក់ថា ពាណិជ្ជកម្មទំនិញសកល បានងើបឡើងវិញយ៉ាងរហ័ស និងខ្ពស់ជាងការរំពឹងទុក ប៉ុន្តែ ភាពខុសគ្នានៅតាមតំបន់ នៅតែមានគម្លាតធំ។ ជាក់ស្តែង ការនាំចូលនៅក្នុងអាស៊ី សម្រាប់ឆ្នាំ២០២១ ត្រូវបានប៉ាន់ស្មានមានកំណើន ៩,៤% ធៀបនឹងឆ្នាំ២០១៩ ខណៈដែល ការនាំចូលនៃប្រទេសមានការអភិវឌ្ឍទាប ធ្លាក់ចុះ ១,៦%។

ទន្ទឹមនេះដែរ អង្គការពាណិជ្ជកម្មពិភពលោក ក៏បាននិយាយថា ដោយសារតែមូលដ្ឋានទាបជាងមុន ពាណិជ្ជ-កម្មទំនិញសម្រាប់ត្រីមាសទី២ ឆ្នាំ២០២១ មានកំណើន ២២% បើធៀបនឹងត្រីមាសដដែលឆ្នាំ២០២០។ ចំណែកឯ ត្រីមាសទី៣ និងត្រីមាសទី៤ មានកំណើន ១០,៩% និង ៦,៦% រៀងគ្នា ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០២០ ដែលនេះ មួយផ្នែកបណ្តាលមកពីការងើបយ៉ាងរហ័សនៃពាណិជ្ជកម្មនៅ ២ត្រីមាសចុងក្រោយនៃឆ្នាំ២០២០។ គួរបញ្ជាក់ថា ដើម្បីសម្រេចបាននូវការព្យាករសម្រាប់ឆ្នាំ២០២១ ត្រូវការកំណើន ០,៨% ប្រចាំត្រីមាស (ធៀបនឹងត្រីមាសមុន ក្នុងឆ្នាំដដែល) សម្រាប់ឆមាសទី២ នេះ។ ដោយឡែក ពាណិជ្ជកម្មសេវាកម្ម នៅតែស្ថិតពីក្រោយពាណិជ្ជកម្មទំនិញ ជាពិសេស សេវាកម្មពាក់ព័ន្ធនឹងទេសចរណ៍ និងការកម្សាន្ត៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ World Economic Times ចេញផ្សាយ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០២១*

## បញ្ហាកង្វះថាមពលកំពុងកើតឡើងនៅក្នុងប្រទេសចិន



*ប្រភព ៖ ខេមបូណ្ឌមីស*

ការបង្អាក់ការប្រើប្រាស់ និងផ្គត់ផ្គង់ថាមពលអគ្គិសនីនៅទូទាំងប្រទេសចិនកំពុងបង្កជាបញ្ហាប្រឈមដល់ខ្សែសង្វាក់ផលិតកម្ម និងផ្គត់ផ្គង់។ មូលហេតុមួយដែលចំបង គឺការប្តេជ្ញាចិត្តការពារផ្នែកបរិស្ថាន ដោយសារតែថាមពលជាងពាក់កណ្តាលដែលផ្គង់ផ្គង់ប្រទេសចិន ត្រូវបានផលិតចេញពីធ្យូងថ្ម។ ថាមពលផលិតចេញពីធ្យូងថ្មនេះដែរ ជាថាមពលដែលបំផ្លាញដល់បរិស្ថានធ្ងន់ធ្ងរ។ កត្តាមួយទៀតដែលធ្វើឱ្យមានការកាត់ផ្តាច់ថាមពលដែរនោះគឺ តម្លៃធ្យូងថ្មបានហក់ឡើងខ្លាំងនៅមួយរយៈចុងក្រោយនេះ។ យោងតាមអង្គការតាមដានឧស្ម័នកាបូនិក(ទីស្នាក់ការនៅប្រទេសអង់គ្លេស) ៨០%នៃរោងចក្រប្រើធ្យូងថ្មនៅបរទេសគឺជាការវិនិយោគរបស់ក្រុមហ៊ុនចិន ហើយចិនក៏ជាប្រទេសបញ្ចេញឧស្ម័នកាបូនិកច្រើនជាងគេ ទៅក្នុងបរិយាកាសផែនដី ដែលប្រការនេះហើយទើបសហគមន៍អន្តរជាតិកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះការសន្យា និង កិច្ចខិតខំប្រឹងប្រែងរបស់ចិន ក្នុងការកាត់បន្ថយការប្រើប្រាស់ធ្យូងថ្ម។ ក្រុងប៉េកាំងក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចឱ្យបាននូវការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិកឱ្យបានមុនឆ្នាំ២០៣០ និងសម្រេចឱ្យបានកម្មវត្ថុអព្យាក្រឹតកាបូន ឬកាត់បន្ថយ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឱ្យដល់កម្រិតសូន្យនៅឆ្នាំ២០៦០។ បន្ថែមពីលើការប្រើប្រាស់ថាមពលចេញពីធ្យូងថ្មដ៏ច្រើនសន្ធឹកសន្ធាប់ រោងចក្រឧស្សាហកម្មក្នុងប្រទេសចិនភាគច្រើនបានប្រើប្រាស់ថាមពលអគ្គិសនីខ្ជះខ្ជាយ។ ជាក់ស្តែងនៅខែសីហា អាជ្ញាធរក្នុងខេត្តឧស្សាហកម្មចំនួន៣រួមមាន ខេត្តជាំងស៊ូ ហ្គ័ងតុង និង ហឺប៉ី បានចេញលិខិតព្រមានទៅរោងចក្រឧស្សាហកម្ម ពីការប្រើប្រាស់ថាមពលលើសអត្រាកំណត់របស់អាជ្ញាធរ។

នៅខេត្តជាំងស៊ូ ដែលជាមជ្ឈមណ្ឌលឧស្សាហកម្ម និងបច្ចេកវិទ្យារបស់ប្រទេសចិន មានក្រុមហ៊ុនផលិតមួយចំនួនត្រូវបានគេបញ្ជាឱ្យកាត់បន្ថយការប្រើប្រាស់ថាមពលរបស់ពួកគេ សម្រាប់ខែកញ្ញាចំនួនពី១០% ទៅ ៣០% តិចជាងកំរិតធម្មតា។ ស្របពេលដែលសេដ្ឋកិច្ចចិនកំពុងស្ថិតក្នុងភាពមិនច្បាស់លាស់ក្រោយក្រុមហ៊ុនអចលនទ្រព្យ Evergrande កំពុងស្ថិតក្នុងវិបត្តិហិរញ្ញវត្ថុ បញ្ហាថាមពលនេះអាចជាបន្ទុកមួយទៀតសម្រាប់ក្រុងប៉េកាំង និងអាចដាក់សម្ពាធថ្មីមួយទៀតសម្រាប់សេដ្ឋកិច្ចរបស់មហាអំណាចសេដ្ឋកិច្ចទី២ ដែរ។ ធនាគារពិភពលោកក្នុងរបាយការណ៍ថ្មីមួយរបស់ខ្លួនបានបន្តរក្សាការព្យាករណ៍កំណើនសេដ្ឋកិច្ចចិនក្នុងរង្វង់ ៨,៥%។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី០២ ខែតុលា ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០១ ខែតុលា ឆ្នាំ២០២១

- កំណើនអត្រានិកម្មភាព នៅក្នុងប្រទេសទួគីនៅក្នុងខែកក្កដាឆ្នាំ ២០២១
- កំណើនផលិតកម្មឧស្សាហកម្មនៅប្រទេសអ៊ីតាលី ក្នុងខែកក្កដាឆ្នាំ ២០២១ ធៀបនឹងខែដូចគ្នាក្នុងឆ្នាំមុន

ថ្ងៃអង្គារ ទី១២ ខែតុលា ឆ្នាំ២០២១

- ធនាគារកូរ៉េបានដំឡើងអត្រាមូលដ្ឋានរបស់ខ្លួន
- កំណើនអត្រាអនិកម្មភាពនៅចក្រភពអង់គ្លេសនៅខែមិថុនាឆ្នាំ ២០២១

ថ្ងៃពុធ ទី១៣ ខែតុលា ឆ្នាំ២០២១

- អត្រានិកម្មភាព នៅកូរ៉េខាងត្បូងបានធ្លាក់ចុះមកត្រឹម ២,៨% ក្នុងខែសីហាឆ្នាំ ២០២១
- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅអាល្លឺម៉ង់ នៅខែកញ្ញាឆ្នាំ ២០២១ ធៀបនឹងខែមុន

ថ្ងៃព្រហស្បតិ៍ ទី១៤ ខែតុលា ឆ្នាំ២០២១

- កំណើនការនាំចេញរបស់កូរ៉េខាងត្បូង នៅក្នុងខែសីហាឆ្នាំ ២០២១
- កំណើនការនាំចូលរបស់កូរ៉េខាងត្បូង នៅខែសីហាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី១៥ ខែតុលា ឆ្នាំ២០២១

- អត្រាអតិផរណាប្រចាំឆ្នាំនៅប្រទេសអាហ្សង់ទីនបានធ្លាក់ចុះ ក្នុងខែសីហាឆ្នាំ ២០២១
- អតិរេកពាណិជ្ជកម្មនៅតំបន់ចាយប្រាក់អឺរ៉ូបានរួមតូច ខែកក្កដាឆ្នាំ ២០២១៕